## ក្រម Lieber (Lieber Code)

ច្បាប់មនុស្សធម៌អន្តរជាតិ មានប្រភពនិងវិវឌ្ឍន៍ មកដល់ពេល រងឥទ្ធិពលពីក្រមព្រៀងដោយសាស្ត្រាចារ្យ Francis Lieber និងត្រូវបានអនុម័ត ជាបទបញ្ជាទូទៅលេខ ១០០ ដោយប្រធានាធិបតី Lincoln ក្នុងឆ្នាំ ១៨៦៣ ហើយដែលត្រូវបានហៅថា Lieber Code។

ក្រមនេះ មានឥទ្ធិពលលើសន្ធិសញ្ញាបន្តបន្ទាប់មកទៀតពាក់ព័ន្ធនឹងច្បាប់សង្គ្រាម ទោះបីសន្ធិសញ្ញាទាំងនោះ មិនទាន់ត្រូវបានអនុម័តនៅឡើយ ហើយត្រូវបានបញ្ជាក់ឡើងវិញក្នុង Martens Clause។

ក្រមបានចែងនូវវិធានចម្បងមួយចំនួន ដែលត្រូវបានប្រើក្នុងពេលបច្ចុប្បន្ន ដូចជាការបំផ្លាញទ្រព្យក្នុងករណីមានភាពចាំបាច់ខាងយោធា (military necessity) ការការពារជនស៊ីវិល (civilian)។ បន្ថែមពីលើនេះ ក្រមបានចែងអំពីអត្ថន័យនៃពាក្យ "ឈ្លើយសឹក" (prisoner of war) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 409-410)។